ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
**អគ្គនាយកដ្ឋានកៅស៊ូ**

លេខ: [illegible] អក.ចស

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ [illegible] ស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២០

## សូមគោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**កម្មវត្ថុ** ៖ របាយការណ៍ស្ដីពីស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំឆមាសទី១ ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត។
**ជូនភ្ជាប់** ៖-របាយការណ៍ស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំឆមាសទី១ ឆ្នាំ២០២០...........ចំនួន០១ច្បាប់
-តារាងស្ថានភាពផលិតកម្មកៅស៊ូ និងតារាងស្ថានភាពធុរកិច្ចផលិតផលកៅស៊ូស្ងួត ប្រចាំឆមាសទី១ ឆ្នាំ២០២០ ..........................................................................ចំនួន០២ច្បាប់។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបអំពីលទ្ធផលការងារសម្រេចបានរបស់អគ្គនាយកដ្ឋានកៅស៊ូប្រចាំឆមាសទី១ ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្តដោយសង្ខេបដូចខាងក្រោម៖

១-ផ្ទៃដីកៅស៊ូសរុបមានចំនួន៤០៤ ៧០១ហិកតា ក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន២៥០ ១០៧ហិកតា ស្មើនឹង៦២% និងផ្ទៃដីថែទាំមានចំនួន១៥៤ ៥៩៤ហិកតា ស្មើនឹង៣៨%។

២-ផលិតផលជ័រកៅស៊ូក្នុងខែមានចំនួន២៨ ១៦៣តោន កើនឡើងចំនួន២ ៤៦០តោន ស្មើនឹង១០% ធៀបនឹងខែមុននិងបានកើនឡើងចំនួន៥ ៣០៥តោនស្មើនឹង២៣%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។ ផលិតផលជ័រកៅស៊ូមកដល់ខែនេះ មានចំនួន១២៦ ០៩៩តោន បានកើនឡើងចំនួន២០ ៥៦៣តោន ស្មើនឹង១៩%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៣-បរិមាណបញ្ចេញលក់ក្នុងខែមានចំនួន២៥ ៩៥៣តោន កើនឡើងចំនួន៥២៧តោន ស្មើនឹង២%ធៀបនឹងខែមុននឹងបានកើនឡើងចំនួន៤ ៣៧០តោនស្មើនឹង២០%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។ បរិមាណបញ្ចេញលក់មកដល់ខែនេះមានចំនួន១២៣ ១៥១តោន បានកើនឡើងចំនួន១៨ ៨៤១តោន ស្មើនឹង១៨%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៤-តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងខែថ្លៃ១ ២៧៥ដុល្លារ/តោន បានកើនឡើងចំនួន៨៤ដុល្លារ/តោនស្មើនឹង៧,០២%ធៀបនឹងខែមុន និងបានថយចុះ១២១ដុល្លារ/តោនស្មើនឹង៨,៦៨%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។តម្លៃលក់កៅស៊ូមធ្យមគិតដល់ខែនេះថ្លៃ១ ៣០៥ដុល្លារ/តោន បានថយចុះចំនួន៣៣ដុល្លារ/តោនស្មើនឹង២,៤៧%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៥-តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅចម្ការ គឺទឹកជ័រ (DRC 100%) ថ្លៃ៤ ០៥០-៤ ៥០០រ/គ.ក្រ(បានថយចុះ១០៣រ/គ.ក្រ ធៀបនឹងខែមុន) និងជ័រកក (DRC 50%) ថ្លៃ១ ៨៥០-២ ២៧៥រ/គ.ក្រ បានកើនឡើងចំនួន១០៦រ/គ.ក្រ ធៀបនឹងខែមុន) អាស្រ័យតាមតំបន់។

៦-ទិសដៅបន្ត៖ ខិតខំអនុវត្តទិសដៅការងារដែលបានគ្រោងទុកឲ្យបានសម្រេចលទ្ធផលល្អ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំបាទសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបជារបាយការណ៍ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**

**ប៉ុល សុផា**

**ចម្លងជូន៖**
- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក
- ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុក

"ដើម្បីជូនជ្រាប"
- នាយកដ្ឋានកិច្ចការរដ្ឋបាល កសក.
- នាយកដ្ឋានផែនការ និងស្ថិតិ កសក.
- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់ចម្ការកៅស៊ូកសិឧស្សាហកម្ម

"ដើម្បីជ្រាប"
- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
**អគ្គនាយកដ្ឋានកៅស៊ូ**

# របាយការណ៍សរុប
# ស្តីពី
# ស្ថានភាពការងាររបស់អគ្គនាយកដ្ឋានកៅស៊ូ ប្រចាំឆមាសទី១ ឆ្នាំ២០២០
# និងទិសដៅអនុវត្តបន្ត

## ១.សេចក្តីផ្តើម

ក្នុងឆ្នាំ២០២០ នេះអគ្គនាយកដ្ឋានកៅស៊ូបានអនុវត្តការងារចម្បងៗ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ទាំងការងារចរន្ត ការងារអនុវត្តគម្រោងថវិកាតាមកម្មវិធី ការងារដាំដុះ ថែទាំកូនកៅស៊ូថ្មី ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ច ទាំងកៅស៊ូគ្រួសារនិងកៅស៊ូកសិឧស្សាហកម្ម និងការងារផ្សេងៗទៀតបានដំណើរការជាធម្មតា។ ជាលទ្ធផលការងារសំខាន់ៗដែលអគ្គនាយកដ្ឋានកៅស៊ូសម្រេចបានក្នុងឆមាសទី១ ឆ្នាំ២០២០ មានខ្លឹមសារលម្អិតជូនដូចខាងក្រោមៈ

## ២.លទ្ធផលការងារសម្រេចបាន

### ២.១ ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ចកៅស៊ូ

#### ២.១.១ ផ្ទៃដីកៅស៊ូ

ផ្ទៃដីកៅស៊ូសរុបមានចំនួន៤០៤ ៧០១ ហិកតា ដែលក្នុងនោះៈ ផ្ទៃដីចៀរជ័រមានចំនួន២៥០ ១០៧ហិកតា ស្មើនឹង៦២% និងផ្ទៃដីថែទាំមានចំនួន១៥៤ ៥៩៤ហិកតា ស្មើនឹង៣៨%។

#### ២.១.២ ផលិតកម្ម

- ផលិតផលជ័រកៅស៊ូសម្រេចបានប្រចាំខែមិថុនា ឆ្នាំ២០២០ មានចំនួន២៨ ១៦៣តោន បានកើនឡើងចំនួន២ ៤៦០តោនស្មើនឹង១០%ធៀបនឹងខែមុននិងបានកើនឡើងចំនួន៥ ៣០៥តោនស្មើនឹង២៣%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

- ផលិតផលជ័រកៅស៊ូសរុបគិតមកដល់ខែមិថុនា ឆមាសទី១ ឆ្នាំ២០២០ សម្រេចបានចំនួន១២៦ ០៩៩តោន បានកើនឡើងចំនួន២០ ៥៦៣តោន ស្មើនឹង១៩% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

#### ២.១.៣ ធុរកិច្ចកៅស៊ូ

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូសម្រេចបានក្នុងខែមិថុនា ឆ្នាំ២០២០ មានចំនួន២៥ ៩៥៣តោន បានកើនឡើងចំនួន៥២៧តោន ស្មើនឹង២%ធៀបនឹងខែមុននិងបានកើនឡើងចំនួន៤ ៣៧០តោនស្មើនឹង២០%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

- បរិមាណបញ្ចេញលក់សរុបគិតមកដល់ខែមិថុនា ឆមាសទី១ ឆ្នាំ២០២០ សម្រេចបានចំនួន១២៣ ១៥១តោន កើនឡើងចំនួន១៨ ៨៤១តោន ស្មើនឹង១៨%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

- តម្លៃលក់មធ្យមជ័រកៅស៊ូក្នុងខែមិថុនា ឆ្នាំ២០២០ មានចំនួន ១ ២៧៥ដុល្លារ/តោន បានកើនឡើងចំនួន៨៤ដុល្លារ/តោន ស្មើនឹង៧,០២%ធៀបនឹងខែមុន និងបានថយចុះចំនួន១២១ដុល្លារ/តោនស្មើនឹង៨,៦៨%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) ២៣ ៦៧២២ ៥៩០
National Road No.6A, Phum Bakkheng, Sangkat Prek Leap, Khan Chroy Changva, Phnom Penh, Cambodia
Phone: (855) 23 6722 590, Email: gdr.maff@gmail.com

- តម្លៃលក់កៅស៊ូជាមធ្យមគិតមកដល់ខែមិថុនា ឆមាសទី១ ឆ្នាំ២០២០ គឺ១ ៣០៥ ដុល្លារ/តោន បានថយចុះចំនួន ៣៣ ដុល្លារ/តោន ស្មើនឹង២,៤៧% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅចម្ការ គឺទឹកជ័រ (DRC 100%) ថ្លៃ៤ ០៥០-៤ ៥០០រ/គ.ក្រ(បានថយចុះ ១០៣រ/គ.ក្រ ធៀបនឹងខែមុន) និងជ័រកក (DRC 50%) ថ្លៃ១ ៨៥០-២ ២៧៥រ/គ.ក្រ បានកើនឡើងចំនួន១០៦រ/គ.ក្រ ធៀបនឹងខែមុន) អាស្រ័យតាមតំបន់។

## ២.២. ការងារចរន្តនិងការអនុវត្តគម្រោងសកម្មភាពថវិកាតាមកម្មវិធី

### ២.២.១. ការងារចរន្ត

- ប្រជុំរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តចំនួន១លើក
- ប្រជុំពិភាក្សាកែសម្រួលសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតបង្កើតរោងចក្រសិប្បកម្មកែច្នៃកៅស៊ូ និងអនុផលកៅស៊ូចំនួន១លើក
- ចុះបំពេញបេសកកម្មនៅខេត្តប៉ៃលិន ដើម្បីបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ
- ចុះតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគសម្បទានដីសេដ្ឋកិច្ចលើដំណាំកៅស៊ូ នៅខេត្តកោះកុង ខេត្តពោធិ៍សាត់ និងខេត្តក្រចេះ
- ចុះតាមដានការអនុវត្តថវិកាកម្មវិធីលើនាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ នៅខេត្តស្ទឹងត្រែង
- រៀបចំពិនិត្យ និងបូកសរុបគម្រោងសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២១
- បានចុះផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃដល់សហគមន៍កៅស៊ូគ្រួសារនៅខេត្តស្ទឹងត្រែង
- បានចុះបើកវគ្គបណ្តុះបណ្តាលនិងផ្សព្វផ្សាយអំពីទីផ្សារកៅស៊ូដល់កសិករគ្រួសារនៅខេត្តស្ទឹងត្រែង
- ប្រជុំពិនិត្យនិងសម្រេចព្រឹត្តិបត្រកៅស៊ូធម្មជាតិប្រចាំខែមេសា វឌ្ឍនភាពខែឧសភា និងលើកទិសដៅខែមិថុនា ឆ្នាំ២០២០
- បានបោះពុម្ពព្រឹត្តិបត្រប្រចាំខែមេសាចំនួន១៨០ច្បាប់
- តាមដានត្រួតពិនិត្យ ស្រាវជ្រាវអំពីថ្លៃកៅស៊ូនៅទីផ្សារក្នុងនិងក្រៅស្រុកប្រមូល និងចងក្រងទិន្នន័យតម្លៃទិញ-លក់កៅស៊ូធម្មជាតិប្រចាំថ្ងៃ សប្តាហ៍ និងប្រចាំខែក្នុងតំបន់នីមួយៗ
- ផ្សព្វផ្សាយពត៌មានអំពីនិន្នាការថ្លៃកៅស៊ូនៅទីផ្សារក្នុងនិងក្រៅប្រទេសតាមវិទ្យុ ដើម្បីជំរុញថ្លៃលក់ជ័រកៅស៊ូឱ្យបានប្រសើរ
- បានប្រមូលទិន្នន័យ និងរៀបចំតម្លៃកៅស៊ូធម្មជាតិសម្រាប់ផ្សាយប្រចាំសប្តាហ៍តាមវិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា(FM103.5)ចំនួន០៤ដងក្នុងមួយខែ(១សប្តាហ៍១ដង) និងបានផ្សាយបន្តផ្ទាល់ទៅតាមបណ្តាខេត្តចំនួន៤ខេត្ត គឺខេត្តបាត់ដំបង(FM106.3) ខេត្តកំពង់ចាម(FM99.3) ខេត្តកំពង់ធំ(FM104) និង ខេត្តសៀមរាប(FM107) រៀងរាល់ថ្ងៃចន្ទ វេលាម៉ោង១០ព្រឹក។

### ២.២.២. ការចំណាយថវិកាតាមគម្រោងកម្មវិធី

ការចំណាយថវិកាក្នុងខែមិថុនា ឆ្នាំ២០២០ មានចំនួន៨៩ ៣៤២ ០០០រៀល។ បើគិតរហូតមកដល់ខែមិថុនា ឆមាសទី១នេះមានចំនួន៥៦៨ ៣២៤ ១១៨រៀល ស្មើនឹង៤៣,៤៥ ភាគរយនៃផែនការក្រោយធ្វើវិចារណកម្មការចំណាយថវិកាទាំងពីរលើកមានចំនួន១ ៣០៧ ៩០០ ០០០រៀល។

២.២.៣. ការប្រមូលចំណូលថវិកា

ការប្រមូលចំណូលថ្លៃឈ្នួលដីអវិនិយោគចម្ការកៅស៊ូរដ្ឋទាំង៧ ចម្ការកៅស៊ូរដ្ឋឡាបានសៀកខេត្តរតនគីរី និងក្រុមហ៊ុននីហរ័ណ អាហរ័ណកៅស៊ូក្នុងខែមិថុនា ឆ្នាំ២០២០ ពុំមានទេ។ បើគិតរហូតមកដល់ខែមិថុនាឆមាសទី១នេះអនុវត្តបានចំនួន៥៦៤ ២៣១ ២០២រៀល ស្មើនឹង៣៦,០៣ភាគរយនៃផែនការ។

## ៣. ទិសដៅបន្ត

- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកៅស៊ូ
- ត្រៀមចុះចងក្រងបង្កើតសហគមន៍កសិករកៅស៊ូគ្រួសារ
- បន្តចុះបើកវគ្គសិក្ខាសាលាផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូដល់មន្ត្រីបង្គោល
- បន្តចុះពិនិត្យ និងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច
- បន្តអនុវត្តគម្រោងផែនការសកម្មភាពថវិកាកម្មវិធីសម្រាប់ឆ្នាំ២០២០
- បន្តរៀបចំគម្រោងផែនការសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២១
- បញ្ចប់សេចក្ដីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០
- បន្តខិតខំធ្វើទំនាក់ទំនងកិច្ចសហប្រត្តិបត្តិការជាមួយដៃគូរអភិវឌ្ឍ ទីភ្នាក់ងារកៅស៊ូ និងអង្គការកៅស៊ូអន្តរជាតិនានាក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្ត្រ
- បន្តរៀបចំផែនការសកម្មភាពការងារសំណើគម្រោង និងទស្សនាទាននៃគម្រោងពាក់ព័ន្ធនឹងវិស័យឧស្សាហកម្មកៅស៊ូធម្មជាតិ
- បន្តតាមដានលើវឌ្ឍនភាព នៃកិច្ចសហប្រត្តិបត្តិការជាមួយបណ្ដាប្រទេសជាដៃគូរ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូបានប្រគល់អោយ។

ថ្ងៃអង្គារ ៩ រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០២០

**ប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម**

ឃួន_ផល្លា

**បានឃើញនិងឯកភាព**

**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**

**អគ្គនាយករង**

ចាន់_វឌ្ឍនា

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម

ជាតិ សាសនា ព្រះមហាក្សត្រ

## ស្ថានភាពផលិតកម្មកៅស៊ូប្រចាំឆមាសទី១ ឆ្នាំ២០២០

តារាងទី១

| ល.រ | ចម្ការកៅស៊ូ | ផ្ទៃដី(ហិកតា) | | | ឆ្នាំ២០១៩ | | | | សន្និធិដើមឆ្នាំ | ឆ្នាំ២០២០ | | | | ប្រៀបធៀប | | | | | | | | | | | | | | សន្និធិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ផលិតផល(តោន) | | បញ្ចេញលក់(តោន) | | | ផលិតផល(តោន) | | បញ្ចេញលក់(តោន) | | ខែមុន | | | | | | រយៈពេលដូចគ្នាឆ្នាំមុន | | | | | | | | |
| | | ចៀរជ័រ | ថែទាំ | សរុប | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ផ្ទៃដីសរុប | | ផលិតផល | | បញ្ចេញលក់ | | ផលិតផល | | | | បញ្ចេញលក់ | | | | |
| | | | | | | | | | | | | | | | | | | | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | | |
| | | | | | | | | | | | | | | ហិកតា | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | |
| | I. កៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 670 | 132 | 801 | 41 | 208 | 50 | 150 | 158 | 33 | 153 | - | 15 | 0 | 0 | -1 | -2 | 0 | 0 | -8 | -19 | -55 | -26 | -50 | 0 | -135 | -90 | 296 |
| 2 | ក្រុមហ៊ុនសុគន្ធីកា អ៊ិនវេសមេន គ្រុប | 11.287 | 3.262 | 14.549 | 1.443 | 6.495 | 1.116 | 6.724 | 1.093 | 1.639 | 7.161 | 1.374 | 6.768 | 0 | 0 | 42 | 3 | -834 | -38 | 196 | 14 | 667 | 10 | 257 | 23 | 44 | 1 | 1.486 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 1.259 | 1.106 | 2.365 | 154 | 645 | 126 | 672 | 21 | 108 | 466 | 168 | 483 | 0 | 0 | 32 | 42 | 63 | 60 | -46 | -30 | -180 | -28 | 42 | 33 | -189 | -28 | 4 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 6.004 | 1.912 | 7.916 | 445 | 1.633 | 412 | 1.892 | 618 | 518 | 1.827 | 307 | 1.822 | 0 | 0 | 36 | 7 | -215 | -41 | 73 | 16 | 193 | 12 | -105 | -26 | -70 | -4 | 623 |
| 5 | ក្រុមហ៊ុនស៊ីហ្វ រ៉ាប់ប៊ើ លីមីតធីត(រតនគិរី) | 306 | 2.418 | 2.724 | 34 | 99 | 49 | 70 | 47 | 52 | 149 | - | 135 | 0 | 0 | 29 | 124 | -24 | 0 | 18 | 53 | 50 | 50 | -49 | 0 | 65 | 92 | 61 |
| 6 | ក្រុមហ៊ុនស៊ីហ្វ វីសសស់ លីមីតធីត(ស្នួល) | 4.174 | 76 | 4.250 | 387 | 1.410 | 369 | 1.417 | 1.911 | 416 | 1.393 | 223 | 1.961 | 0 | 0 | 1 | 0 | 223 | 100 | 28 | 7 | -17 | -1 | -145 | -39 | 544 | 38 | 1.344 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ិនធើណេស៊ិនណល | 3.908 | 278 | 4.186 | 230 | 899 | | 1.302 | 706 | 296 | 1.023 | 381 | 1.516 | 0 | 0 | 28 | 10 | 171 | 81 | 66 | 29 | 124 | 14 | 381 | 100 | 214 | 16 | 214 |
| 8 | ក្រុមហ៊ុនអានម៉ាទី គ្រុប(ចម្ការអណ្តូង) | 3.312 | 1.570 | 4.882 | 178 | 726 | 160 | 823 | 613 | 184 | 651 | - | 703 | 0 | 0 | -18 | -9 | -203 | 0 | 6 | 3 | -74 | -10 | -160 | 0 | -120 | -15 | 561 |
| 9 | ក្រុមហ៊ុនអានម៉ាទី គ្រុប(ពាមជាំង+មោសហែក) | 1.918 | 1.119 | 3.037 | 147 | 432 | 180 | 530 | 380 | 91 | 345 | - | 409 | 0 | 0 | 9 | 12 | -170 | 0 | -56 | -38 | -87 | -20 | -180 | 0 | -121 | -23 | 316 |
| 10 | ក្រុមហ៊ុនក្រេក(ខេមបូឌា) ខូអិលធីឌី | 4.639 | 159 | 4.798 | 599 | 2.488 | 420 | 2.730 | 550 | 526 | 2.229 | - | 1.940 | 0 | 0 | 2 | 0 | -785 | 0 | -73 | -12 | -259 | -10 | -420 | 0 | -790 | -29 | 839 |
| | សរុប ក | 37.477 | 12.033 | 49.510 | 3.658 | 15.036 | 2.882 | 16.311 | 6.097 | 3.863 | 15.399 | 2.453 | 15.751 | 0 | 0 | 160 | 4 | -1.773 | -42 | 205 | 6 | 363 | 2 | -430 | -15 | -559 | -3 | 5.744 |
| ខ | ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | 79.361 | 114.727 | 194.088 | 7.800 | 36.800 | 7.500 | 35.300 | 3.653 | 10.200 | 46.500 | 9.800 | 44.900 | 0 | 0 | 1.000 | 11 | 1.000 | 11 | 2400 | 31 | 9.700 | 26 | 2.300 | 31 | 9.600 | 27 | 5.253 |
| | សរុបI=ក+ខ | 116.838 | 126.760 | 243.599 | 11.458 | 51.836 | 10.382 | 51.611 | 9.750 | 14.063 | 61.899 | 12.253 | 60.651 | 0 | 0 | 1.160 | 9 | -773 | -6 | 2605 | 23 | 10.063 | 19 | 1.870 | 18 | 9.041 | 18 | 10.997 |
| | II. កៅស៊ូគ្រួសារ | 133.269 | 27.834 | 161.103 | 11.400 | 53.700 | 11.200 | 52.700 | 7.076 | 14.100 | 64.200 | 13.700 | 62.500 | 0 | 0 | 1.300 | 10 | 1.300 | 10 | 2700 | 24 | 10.500 | 20 | 2.500 | 22 | 9.800 | 19 | 8.776 |
| | សរុបរួមI+II | 250.107 | 154.594 | 404.701 | 22.858 | 105.536 | 21.582 | 104.311 | 16.826 | 28.163 | 126.099 | 25.953 | 123.151 | 0 | 0 | 2.460 | 10 | 527 | 2 | 5305 | 23 | 20.563 | 19 | 4.370 | 20 | 18.841 | 18 | 19.773 |

បញ្ជាក់៖

(១) ផ្ទៃដីសរុបមានចំនួន៤០៤ ៧០១ហត ( ផ្ទៃដីចៀរជ័រមានចំនួន២៥០ ១០៧ហត ថែទាំមានចំនួន១៥៤ ៥៩៤ហត)។

(២) ផលិតផលសរុបចំនួន២៨ ១៦៣តោន បានកើនឡើងចំនួន២ ៤៦០តោន(១០%) ធៀបនិងខែមុននិងបានកើនឡើងចំនួន៥ ៣០៥តោន(២៣%)ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៣) រហូតមកដល់ខែមិថុនា ឆមាសទី១ ឆ្នាំ២០២០ ផលិតផលសរុបចំនួន១២៦ ០៩៩តោន បានកើនឡើងចំនួន២០ ៥៦៣តោន(១៩%)ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៤) ការបញ្ចេញលក់សរុបចំនួន២៥ ៩៥៣តោន បានកើនឡើងចំនួន៥២៧តោន(២%)ធៀបនិងខែមុននិងបានកើនឡើងចំនួន៤ ៣៧០តោន(២០%)រយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៥) រហូតមកដល់ខែមិថុនា ឆមាសទី១ ឆ្នាំ២០២០ ការបញ្ចេញលក់សរុបចំនួន១២៣ ១៥១តោន បានកើនឡើងចំនួន១៨ ៨៤១តោន(១៨%) ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៦) សន្និធិចុងគ្រាមានចំនួន១៩ ៧៧៣តោន

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

ចាន់_វឌ្ឍនា

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម

ឃួន_ឥន្លា

ថ្ងៃ ៩ ៣ ១៥ ខែ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០២០
អ្នកធ្វើតារាង

ហួន ស្រីនឹម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

## តារាងស្ថានភាពធុរកិច្ចផលិតផលជ័រកៅស៊ូស្ងួតប្រចាំឆមាសទី១ ឆ្នាំ២០២០

តារាងទី២

| ល.រ | ចម្ការកៅស៊ូ | មិថុនា ២០១៩ | | | | | | មិថុនា ២០២០ | | | | | | ធៀបខែមុន | | | | ធៀបរយៈពេលដូចគ្នានៅឆ្នាំមុន | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បរិមាណ(តោន) | | ទឹកប្រាក់($) | | តម្លៃមធ្យម($/តោន) | | បរិមាណ(តោន) | | ទឹកប្រាក់($) | | តម្លៃមធ្យម($/តោន) | | បរិមាណ | | តម្លៃមធ្យម | | បរិមាណ | | | | តម្លៃមធ្យម | | | |
| | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | | ខែនេះ | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | |
| | | | | | | | | | | | | | | តោន | % | $/តោន | % | តោន | % | តោន | % | $/តោន | % | $/តោន | % |
| | I. កៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 50 | 150 | 64.000 | 193.000 | 1.280 | 1.287 | | 15 | | 14.500 | 0 | 967 | 0 | 0 | 0 | 0,00 | 0 | 0 | -135 | -90 | 0 | 0,00 | -320 | -24,87 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ីនវេសមេន គ្រុប | 1.116 | 6.724 | 1.604.850 | 9.060.393 | 1.437 | 1.347 | 1.374 | 6.768 | 1.693.351 | 8.641.902 | 1.233 | 1.277 | -834 | -37,77 | 28 | 2,32 | 257 | 23,05 | 44 | 0,65 | -205 | -14,25 | -71 | -5,24 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 126 | 672 | 173.040 | 892.710 | 1.373 | 1.328 | 168 | 483 | 199.080 | 600.444 | 1.185 | 1.243 | 63 | 60,00 | -10 | -0,80 | 42 | 33,33 | -189 | -28,13 | -188 | -13,71 | -85 | -6,42 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 412 | 1.892 | 594.384 | 2.587.595 | 1.444 | 1.367 | 307 | 1.822 | 413.364 | 2.607.625 | 1.348 | 1.431 | -215 | -41,24 | 93 | 7,42 | -105 | -25,51 | -70 | -3,72 | -96 | -6,64 | 64 | 4,67 |
| 5 | ក្រុមហ៊ុនស៊ីហ្វ រ៉ាប់ប៊ើ លីមីធីត(រតនគិរី) | 49 | 70 | 58.177 | 82.326 | 1.179 | 1.170 | | 135 | | 141.292 | 0 | 1.045 | 0 | 0 | 0 | 0 | 0 | 0 | 65 | 92,19 | 0 | 0 | -125 | -10,70 |
| 6 | ក្រុមហ៊ុនស៊ីហ្វ វីសសស៍ លីមីធីត(ស្នួល) | 369 | 1.417 | 502.060 | 1.791.170 | 1.361 | 1.264 | 223 | 1.961 | 261.134 | 2.518.814 | 1.169 | 1.285 | 223 | 100,00 | 1.169 | 100,00 | -145 | -39,43 | 544 | 38,39 | -192 | -14,14 | 20 | 1,62 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ីនធើណេស៊ិនណល | | 1.302 | | 1.796.865 | 0 | 1.380 | 381 | 1.516 | 559.804 | 2.128.504 | 1.470 | 1.404 | 171 | 81,33 | 263 | 21,75 | 381 | 100,00 | 214 | 16,42 | 1.470 | 100,00 | 24 | 1,75 |
| 8 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ចម្ការអណ្តូង) | 160 | 823 | 209.900 | 1.008.894 | 1.312 | 1.226 | | 703 | | 835.150 | 0 | 1.188 | 0 | 0 | 0 | 0 | 0 | 0 | -120 | -14,56 | 0 | 0 | -38 | -3,11 |
| 9 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ពាមជាំង) | 180 | 530 | 233.200 | 663.196 | 1.296 | 1.251 | | 409 | | 477.124 | 0 | 1.167 | 0 | 0 | 0 | 0 | 0 | 0 | -121 | -22,90 | 0 | 0 | -84 | -6,69 |
| 10 | ក្រុមហ៊ុនក្រេក(ខេមបូឌា) ខូអិលធីឌី | 420 | 2.730 | 583.800 | 3.647.070 | 1.390 | 1.336 | | 1.940 | | 2.502.060 | 0 | 1.290 | 0 | 0,00 | 0 | 0,00 | 0 | 0,00 | -790 | -28,95 | 0 | 0,00 | -46 | -3,45 |
| | **សរុប ក** | **2.882** | **16.311** | **4.023.411** | **21.723.220** | **1.396** | **1.332** | **2.453** | **15.751** | **3.126.733** | **20.467.414** | **1.275** | **1.299** | **-1.773** | **-41,96** | **84** | **7,02** | **-430** | **-14,90** | **-559** | **-3,43** | **-121** | **-8,68** | **-32** | **-2,43** |
| ខ | ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | 7.500 | 35.300 | 10.469.471 | 47.304.723 | 1.396 | 1.340 | 9.830 | 44.900 | 12.493.266 | 58.648.687 | 1.275 | 1.306 | 1.000 | 11,36 | 84 | 7,02 | 2.300 | 30,67 | 9.600 | 27,20 | -121 | -8,68 | -34 | -2,53 |
| | សរុបI=ក+ខ | 10.382 | 51.611 | 14.492.882 | 69.027.943 | 1.396 | 1.337 | 12.253 | 60.651 | 15.619.998 | 79.116.102 | 1.275 | 1.304 | -773 | -5,93 | 84 | 7,02 | 1.870 | 18,02 | 9.041 | 17,52 | -121 | -8,68 | -33 | -2,47 |
| | II. កៅស៊ូគ្រួសារ | 11.200 | 52.700 | 15.634.411 | 70.596.888 | 1.396 | 1.340 | 13.700 | 62.500 | 17.465.075 | 81.650.680 | 1.275 | 1.306 | 1.300 | 10,48 | 84 | 7,02 | 2.500 | 22,32 | 9.800 | 18,60 | -121 | -8,68 | -33 | -2,48 |
| | **សរុបI+II** | **21.582** | **104.311** | **30.127.293** | **139.624.831** | **1.396** | **1.339** | **25.953** | **123.151** | **33.085.074** | **160.766.782** | **1.275** | **1.305** | **527** | **2,07** | **84** | **7,02** | **4.370** | **20,25** | **18.841** | **18,06** | **-121** | **-8,68** | **-33** | **-2,47** |

**បញ្ជាក់៖**

១. ក្នុងខែមិថុនា ឆ្នាំ២០២០ បរិមាណបញ្ចេញលក់សរុបមានចំនួន២៥ ៩៥៣តោន បានកើនឡើង៥២៧តោន (=២,០៧%)បើធៀបនឹងខែមុន និងបានកើនឡើង៤ ៣៧០តោន(=២០,២៥%)បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

២. ក្នុងខែមិថុនា ឆ្នាំ២០២០ តម្លៃលក់មធ្យមគឺ១ ២៧៥ដុល្លារ/តោន បានកើនឡើងចំនួន៨៤ដុល្លារ/តោន(=៧,០២%) ធៀបនឹងខែមុន ប៉ុន្តែបានថយចុះ១២១ដុល្លារ/តោន (=-៨,៦៨%)បើធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

៣. ក្នុងឆមាសទី១ ឆ្នាំ២០២០ បរិមាណបញ្ចេញលក់សរុបមានចំនួន១២៣ ១៥១តោន បានកើនឡើង១៨ ៨៤១តោន (=+១៨,០៦%)ធៀបរយៈពេលដូចគ្នាឆ្នាំ២០១៩។

៤. ក្នុងឆមាសទី១ ឆ្នាំ២០២០ តម្លៃលក់មធ្យមគឺ១ ៣០៥ដុល្លារ/តោន បានថយចុះ៣៣ដុល្លារ/តោន (=-២,៤៧%) ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩។

បានឃើញ និងឯកភាព
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

យុន កក្កដា

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

ហ៊ិន-សាផន

ថ្ងៃ ... ខែ ... ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២០
អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

# តម្លៃប្រមូលទិញជ័រកៅស៊ូពីកសិករកៅស៊ូគ្រួសារ
## *ខែមិថុនា ឆ្នាំ២០២០*

| ល.រ | ខេត្ត | សប្តាហ៍ទី ១ | | | | | | សប្តាហ៍ទី ២ | | | | | | សប្តាហ៍ទី ៣ | | | | | | សប្តាហ៍ទី ៤ | | | | | | តម្លៃមធ្យមខែ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | ជ័រកក |
| | | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | រ/គ.ក្រ |
| ១ | កំពង់ចាម | 4.400 | 1,08 | → 0 | 2.000 | 0,49 | → 0 | 4.400 | 1,08 | → 0 | 2.000 | 0,49 | → 0 | 4.600 | 1,13 | ↑ 200 | 2.200 | 0,54 | ↑ 200 | 4.600 | 1,13 | → 0 | 2.200 | 0,54 | → 0 | 4.500 | 2100 |
| ២ | ត្បូងឃ្មុំ | 4.000 | 0,98 | ↑ 100 | 1.900 | 0,47 | ↑ 100 | 4.000 | 0,98 | → 0 | 1.900 | 0,47 | → 0 | 4.100 | 1,00 | ↑ 100 | 1.900 | 0,47 | → 0 | 4.100 | 1,00 | → 0 | 2.200 | 0,54 | ↑ 300 | 4.050 | 1975 |
| ៣ | កំពង់ធំ | 4.000 | 0,98 | → 0 | 1.800 | 0,44 | → 0 | 4.000 | 0,98 | → 0 | 1.800 | 0,44 | → 0 | 4.100 | 1,00 | ↑ 100 | 2.000 | 0,49 | ↑ 200 | 4.100 | 1,00 | → 0 | 2.000 | 0,49 | → 0 | 4.050 | 1900 |
| ៤ | រតនគិរី | 4.400 | 1,08 | ↓ 100 | 2.200 | 0,54 | ↑ 200 | 4.400 | 1,08 | → 0 | 2.300 | 0,56 | ↑ 100 | 4.200 | 1,03 | ↓ 200 | 2.200 | 0,54 | ↓ 100 | 4.200 | 1,03 | → 0 | 2.400 | 0,59 | ↑ 200 | 4.300 | 2275 |
| ៥ | ក្រចេះ | | 0,00 | → 0 | 1.900 | 0,47 | ↑ 50 | | 0,00 | → 0 | 1.900 | 0,47 | → 0 | | 0,00 | → 0 | 1.900 | 0,47 | → 0 | | 0,00 | → 0 | 1.900 | 0,47 | → 0 | | 1900 |
| ៦ | មណ្ឌលគិរី | | | | 1.750 | 0,43 | → 0 | | | | 1.750 | 0,43 | → 0 | | | | 1.950 | 0,48 | ↑ 200 | | | | 1.950 | 0,48 | → 0 | | 1850 |
| | តម្លៃមធ្យម | 4.200 | 1,03 | ↓ 40 | 1.925 | 0,47 | ↑ 58 | 4.200 | 1,03 | → 0 | 1.942 | 0,48 | ↑ 17 | 4.250 | 1,04 | ↑ 50 | 2.025 | 0,50 | ↑ 83 | 4.250 | 1,04 | → 0 | 2.108 | 0,52 | ↑ 83 | 4.225 | 2.000 |
| | អត្រាប្តូរប្រាក់ ធនាគារជាតិនៃកម្ពុជា | | 4.072 | | | | | | 4.072 | | | | | | 4.080 | | | | | | 4.084 | | | | | | |

ក្នុងខែមិថុនា ឆ្នាំ២០២០ ថ្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅមាត់ចម្ការ គឺទឹកជ័រគិតជាជ័រស្ងួត ថ្លៃ៤០៥០រ-៤៥០០រ/គ.ក្រ (បានថយចំនួន១៨៣ ធៀបខែមុន) ប៉ុន្តែជ័រកក ថ្លៃ១៨៥០-២២៧៥រ/គ/ក្រ (បានកើនឡើងចំនួន១០៦រ/គ.ក្រ ធៀបខែមុន) អាស្រ័យតាមតំបន់។

**បញ្ជាក់:**

*ប្រភព: ពីអ្នកប្រមូលទិញតាមតំបន់*

*ទឹកជ័រ: គិតជាស្ងួត (DRC)*

*ជ័រកក: DRC ≅ 50%*

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២០
អ្នកធ្វើតារាង

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

ហ៊ិន-សាផន

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

យុន កក្កដា